ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខ៖ ០៦៤ [illegible] /គ.ជ.អ.ប

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួងសម្រាប់រៀបចំផ្ទេរបុគ្គលិក និង រៀបចំមុខតំណែងគ្រប់គ្រងតាមការិយាល័យ និងអង្គភាពនានានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីជួយដល់ គ.ជ.អ.ប. ក្នុងការរៀបចំផ្ទេរបុគ្គលិក និងរៀបចំមុខតំណែងគ្រប់គ្រងតាមការិយាល័យ និងអង្គភាពនានានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗក្នុងដំណាក់កាលនៃការធ្វើសមាហរណកម្មការិយាល័យ និងអង្គភាពនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ចាន់ សុធា** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប | ជាប្រធាន |

២. ឯកឧត្តម **ធ្រាក់ សំអឿន** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល
នៃក្រសួងមហាផ្ទៃ ជាអនុប្រធាន

៣. អគ្គនាយកនៃអគ្គនាយកដ្ឋានមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ ជាអនុប្រធាន

៤. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយរូប ជាសមាជិក

៥. ឯកឧត្តម **តូច ពលពន្លក** ទីប្រឹក្សាក្រសួងមហាផ្ទៃ ជាសមាជិក

៦. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងមហាផ្ទៃ ជាសមាជិក

៧. ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិកនៃក្រសួងមុខងារសាធារណៈ ជាសមាជិក

៨. ប្រធាននាយកដ្ឋានគ្រប់គ្រងក្របខ័ណ្ឌនៃក្រសួងមុខងារសាធារណៈ ជាសមាជិក

៩. ប្រធាននាយកដ្ឋានត្រួតពិនិត្យរដ្ឋបាល និងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល
ក្រសួងមុខងារសាធារណៈ ជាសមាជិក

១០. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិក

១១. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងអភិវឌ្ឍន៍ជនបទ ជាសមាជិក

១២. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងធនធានទឹក និងឧតុនិយម ជាសមាជិក

១៣. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងបរិស្ថាន ជាសមាជិក

១៤. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងរ៉ែ និងថាមពល ជាសមាជិក

១៥. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក

១៦. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

១៧. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាសមាជិក

១៨. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងពាណិជ្ជកម្ម ជាសមាជិក

១៩. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងទេសចរណ៍ ជាសមាជិក

២០. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសមាជិក

២១. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងកិច្ចការនារី ជាសមាជិក

២២. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាសមាជិក

២៣. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងធម្មការ និងសាសនា ជាសមាជិក

២៤. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាសមាជិក

២៥. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាសមាជិក

២៦. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ជាសមាជិក

២៧. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងយុត្តិធម៌ ជាសមាជិក

២៨. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងផែនការ ជាសមាជិក

២៩. ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងព័ត៌មាន ជាសមាជិក

៣០. **លោក មុំ ណារ៉ែន** អនុប្រធានអង្គភាពវិភាគនិងអភិវឌ្ឍន៍

| | | |
|---|---|---|
| | គោលនយោបាយនៃលេខាធិការដ្ឋានគ.ជ.អ.ប. | ជាសមាជិក |
| ៣១. លោក អ៊ុំ ចំរើន | អនុប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៣២. លោក ស៊ិត សូលីដា | អនុប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៣៣. លោក សរ ដារុន | អនុប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៣៤. លោក តូច វីរៈ | ប្រធានការិយាល័យបុគ្គលិកថ្នាក់ក្រោមជាតិ នៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៣៥. លោក ប៊ុន ម៉ានិត | ប្រធានការិយាល័យមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិ នៃលេខាធិការដ្ឋាន គ.ជ.អ.ប. | ជាសមាជិក |
| ៣៦. លោក ហែម សាមឿន | មន្ត្រីការិយាល័យមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិ នៃលេខាធិការដ្ឋាន គ.ជ.អ.ប. | ជាសមាជិក។ |

**ប្រការ ២.-**

ក្រុមការងារអន្តរក្រសួងសម្រាប់រៀបចំផ្ទេរបុគ្គលិក និងរៀបចំមុខតំណែងគ្រប់គ្រងតាមការិយាល័យ និងអង្គភាពនានានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌមានភារកិច្ចដូចខាងក្រោម ៖

- រៀបចំគោលការណ៍ណែនាំសម្រាប់ធ្វើសមាហរណកម្មបុគ្គលិក និងរៀបចំមុខតំណែងគ្រប់គ្រងសម្រាប់ការិយាល័យ ឬអង្គភាពនីមួយៗក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ប្រមូល និងចងក្រងទិន្នន័យបុគ្គលិកដែលបំពេញការងារនៅតាមការិយាល័យ និងអង្គភាពនៅថ្នាក់ក្រុង ស្រុក ខណ្ឌដែលត្រូវធ្វើសមាហរណកម្មមកក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- វិភាគ និងផ្ទៀងផ្ទាត់បុគ្គលិកសម្រាប់ផ្ទេរ និងរៀបចំមុខតំណែងគ្រប់គ្រងសម្រាប់ការិយាល័យ ឬអង្គភាពនីមួយៗក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ពិភាក្សា និងពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការរៀបចំបញ្ជីបុគ្គលិកដែលត្រូវធ្វើសមាហរណកម្ម
- រៀបចំសេចក្តីព្រាងសេចក្តីសម្រេច និងបញ្ជីបុគ្គលិកដែលត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីដាក់ជូន គ.ជ.អ.ប. ពិនិត្យ និងសម្រេច
- សម្របសម្រួល និងតាមដានលើការរៀបចំការផ្ទេរបៀវត្សសម្រាប់បុគ្គលិកដែលបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រៀបចំ និងសម្របសម្រួលដល់ការប្រកាសចូលកាន់មុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្មីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ធ្វើសេចក្តីរាយការណ៍ជូនប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីរៀបចំរបាយការណ៍ និងស្នើសុំគោលការណ៍ដឹកនាំ និងការសម្រេចពី គ.ជ.អ.ប.
- អនុវត្តកិច្ចការផ្សេងទៀតតាមការណែនាំរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ។

**ប្រការ ៣.-**

ក្រុមការងារអន្តរក្រសួងនេះមានរបៀបរបបការងារដូចខាងក្រោម៖

- ចូលរួមកិច្ចប្រជុំជាទៀងទាត់តាមការអញ្ជើញរបស់ប្រធានក្រុមការងារ
- រៀបចំបែងចែកភារកិច្ចដល់សមាជិកក្រុមការងារតាមតម្រូវការ និងការចាំបាច់
- សមាជិកក្រុមការងារម្នាក់ៗអាចប្រើប្រាស់មន្ត្រី បុគ្គលិក មធ្យោបាយ ថវិកានៃអង្គភាពរបស់ខ្លួនដើម្បីអនុវត្តភារកិច្ចដូចបានកំណត់ក្នុងប្រការ២នៃសេចក្តីសម្រេចនេះ។

**ប្រការ ៤.-**

រដ្ឋមន្ត្រីក្រសួងជាសមាជិកគ.ជ.អ.ប. ប្រធានលេខាធិការដ្ឋានគ.ជ.អ.ប. ក្រុមប្រឹក្សានិងគណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សានិងគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.......................ខែ............... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.....០៩.....ខែ.....ធ្នូ.......ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង**

**ជាប្រធាន គ.ជ.អ.ប.**

**សម្តេចក្រឡាហោម ស ខេង**

**<u>កន្លែងទទួល</u> ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាក់ព័ន្ធ
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ។